ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១២៣៦ ឧស.កអកជល

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

ដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ម្ចាស់រោងចក្រ និងសិប្បកម្ម ដែលបាននិងកំពុងដំណើរការធ្វើការកែច្នៃ ការកិនបំបែករ៉ែសំណង់ បម្រើឲ្យវិស័យសំណង់គ្រប់ប្រភេទ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ជ្រាបថា៖

យោងមាត្រា៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា៥៧ នៃអនុក្រឹត្យលេខ៧២អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្ម និងអាជីវកម្មធនធានរ៉ែ គឺ៖ ម្ចាស់រោងចក្រ និងសិប្បកម្ម ដែលកំពុងដំណើរការផលិតកម្ម ការកែច្នៃ ការកិនបំបែករ៉ែសំណង់ បម្រើឲ្យវិស័យសំណង់គ្រប់ប្រភេទ ត្រូវមកធ្វើប្រកាសបង្កើតរោងចក្រ នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬនៅតាមបណ្តាមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត។

ចំពោះម្ចាស់រោងចក្រ និង សិប្បកម្ម ដែលបាននិងកំពុងដំណើរការផលិតកម្ម ការកែច្នៃ ការកិនបំបែករ៉ែសំណង់ បម្រើឲ្យវិស័យសំណង់គ្រប់ប្រភេទ ហើយកំពុងតែប្រើប្រាស់ប្រកាសបង្កើតរោងចក្រ និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ របស់អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនោះ ត្រូវមកសុំធ្វើការផ្លាស់ប្តូរប្រកាសទម្រង់ថ្មី នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬនៅតាមបណ្តាមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត ដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើយ។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់រោងចក្រ និង សិប្បកម្ម ដូចបានជម្រាបជូនខាងលើ នឹងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់ និងមានការទទួលខុសត្រូវចំពោះមុខច្បាប់។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263